# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៩១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **ណឹម ម៉េង** ទីប្រឹក្សាឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងជាប្រធានកិត្តិយសគណៈកម្មការទ្រទ្រង់វិទ្យាល័យ ជា ស៊ីម សាមគ្គី ដែលបានជួយឧបត្ថម្ភថវិកាសំរាប់អភិវឌ្ឍន៍វិស័យសិក្សាធិការ នៅវិទ្យាល័យ ជា ស៊ីម សាមគ្គី រាជធានីភ្នំពេញ រួមមាន : ស្តូបនិងរូបសំណាកព្រះបាទជ័យវរ្ម័នទី៧ សួនច្បារ ដងទង់ជាតិ ខ្លោងទ្វារធំ ០១ តុវេទិកា "តុវាគ្មិន" រៀបក្រាលការ៉ូឡា មុខអាគារទី៩ និងចាក់ដីបំពេញទីធ្លា សរុបថវិកាអស់ចំនួន ២១.៨០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ